ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ...០៦៨ ១,៦,ក..អ.ជ.ប.គ.ញ.

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៦

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខែឧសភា និងលើកទិសដៅការងារខែមិថុនា ឆ្នាំ២០២៦

(ថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៦)

អនុវត្តតាមទិសដៅការងារដែលបានដាក់ចេញកាលពីខែមេសាឆ្នាំ២០២៦កន្លងទៅ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន(អ.ជ.ប.គ.ញ.) ដែលជាសេនាធិការឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសម្របសម្រួល ប្រមូលផ្តុំដឹកនាំ និងអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រកបដោយការយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់ ហើយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែឧសភា ឆ្នាំ២០២៦នេះ ស្ថានភាពនៃបទល្មើសគ្រឿងញៀននៅតែបន្តប្រែប្រួលស្មុគស្មាញ ដោយក្រុមឧក្រិដ្ឋជនគ្រឿងញៀននៅតែបន្តធ្វើសកម្មភាពចរាចរ ដឹកជញ្ជូន ជួញដូរនិងលួចលាក់កែច្នៃគ្រឿងញៀន ក្នុងនោះ បទល្មើសគ្រឿងញៀនធំៗចាប់ពី ១គីឡូក្រាមឡើង ដែលសមត្ថកិច្ចបង្ក្រាបបាន រួមមានបទល្មើសកែច្នៃនូវសារធាតុញៀន ២ករណី នៅខេត្តព្រះសីហនុ ចាប់យកគ្រឿងញៀន **៣០គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ៣នាក់។ បទល្មើសដឹកជញ្ជូន និងជួញដូរគ្រឿងញៀនឆ្លងដែនតាមផ្លូវគោកនិងតាមលម្ហសមុទ្រ ៣ករណី នៅរាជធានីភ្នំពេញ ខេត្តស្ទឹងត្រែង និងខេត្តព្រះសីហនុ ចាប់យកគ្រឿងញៀន **១តោន ៣៧០គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ១១នាក់។ ជាមួយនេះ បទល្មើសរក្សាទុក ដឹកជញ្ជូន និងជួញដូរនូវគ្រឿងញៀនក្នុងផ្ទៃប្រទេស ១១ករណី នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ព្រះសីហនុ កំពង់ចាម និងខេត្តស្វាយរៀង ចាប់យកគ្រឿងញៀន **៣៩គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ២៦នាក់។

**ការកត់សម្គាល់** ក្រៅពីស្ថានភាពនៃបទល្មើសគ្រឿងញៀនខាងលើ ក្នុងក្របខ័ណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ បានបង្ហាញឱ្យឃើញថា ការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀនបានធ្វើសកម្មភាពជាប្រចាំ ការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនបានអនុវត្តកាន់តែសកម្ម និងមានប្រសិទ្ធភាពជាងមុន វិធានការរដ្ឋបាលនិងវិធានការច្បាប់នៅតាមគោលដៅក្លឹបកម្សាន្តនិងទីតាំងសប្បាយដ្ឋាន ត្រូវបានអនុវត្តជាប្រចាំដោយធ្វើកិច្ចសន្យាមិនឱ្យមានការជួញដូរនិងប្រើប្រាស់គ្រឿងញៀន។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ. មានទីតាំងនៅក្នុងបរិវេណទីស្តីការក្រសួងមហាផ្ទៃ, Phone : (855) 23 721 648, (855) 16 721 648, P.O.Box: 151
E-mail: info@nacd.gov.kh Website: www.nacd.gov.kh

ក្នុងទីតាំងអាជីវកម្មរបស់ខ្លួន ហើយកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ តាមរយៈកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ការផ្លាស់ប្តូរព័ត៌មាន និងចែករំលែកបទពិសោធទៅវិញទៅមកត្រូវបានពង្រឹងនិងពង្រីកជាបន្តបន្ទាប់។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

ការងារផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយ និងតាមសហគមន៍ ទទួលបានលទ្ធផលដូចខាងក្រោម៖

#### ១.១. ការងារផ្សព្វផ្សាយអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

បានសម្របសម្រួលនិងអនុវត្តសកម្មភាពការងារផ្សព្វផ្សាយអប់រំនៅតាមប្រព័ន្ធផ្សព្វផ្សាយដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- តាមរយៈគេហទំព័ររបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. (www.nacd.gov.kh) មានការចូលអានចំនួន **១៦៥.៩០៨ដង** (នៅខែមេសា មានចំនួន ១៤៥.៣៩៣ដង) ច្រើនជាង ២០.៥១៥ដង កើនឡើង **១៤,១%**
- ផ្សព្វផ្សាយអប់រំតាមរយៈឃ្លីបវីដេអូខ្លីៗ តាមបណ្តាញទំនាក់ទំនងសង្គម Facebook Page និងកម្មវិធីទូរស័ព្ទដៃ NoDrug របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ឆ្លើយតបចម្ងល់មហាជននៅក្នុងFacebook និងPage របស់នាយកដ្ឋាននិងប្រធាននាយកដ្ឋានផ្សព្វផ្សាយ អប់រំ និងទំនាក់ទំនងសាធារណៈ ពាក់ព័ន្ធការព្យាបាលគ្រឿងញៀននិងចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន ទទួលបានការគាំទ្រគួរកត់សម្គាល់
- សហការសម្របសម្រួលជាមួយស្ថានីយ៍ទូរទស្សន៍ វិទ្យុ និងបណ្តាញព័ត៌មាន ដើម្បីធ្វើការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន។

#### ១.២.ការងារផ្សព្វផ្សាយអប់រំតាមសហគមន៍

បានសហការសម្របសម្រួលនិងអនុវត្តសកម្មភាពការងារផ្សព្វផ្សាយអប់រំនៅតាមសហគមន៍ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ អប់រំ ស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងបារីអេឡិចត្រូនិក ព្រមទាំងជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា នៅខេត្តត្បូងឃ្មុំ និងខេត្តបាត់ដំបង
- សហការជាមួយសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែងនៃក្រសួងសុខាភិបាល រៀបចំពិធីផ្សព្វផ្សាយ អប់រំ ស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងជំរុញការទាញយក និងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ដល់និស្សិតមកពីបណ្តារាជធានី ខេត្ត នៅខេត្តស្ទឹងត្រែង
- ចូលរួមជាមួយគណៈកម្មាធិការសម្របសម្រួល ជំរុញ អនុវត្ត និងត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ រៀបចំពិធីផ្សព្វផ្សាយគោលនយោបាយ គោលការណ៍ ផែនការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងចំណេះដឹងស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀននិងជំរុញការទាញយក និងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ដល់មន្ត្រីរាជការនៃរដ្ឋបាលខេត្តស្ទឹងត្រែង និងខេត្តបាត់ដំបង៖

- សហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំការផ្សព្វផ្សាយ អប់រំ ស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ក្នុងការប្រកួតវោហាកោសល្យក្នុងចំណោមនិស្សិតនិងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម រាជធានីភ្នំពេញ

- ចូលរួមកម្មវិធីតម្រង់ទិសដល់និស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រនគរបាល មុនចុះកម្មសិក្សាតាមបណ្តាស្នងការដ្ឋាននគរបាលរាជធានី ខេត្ត លើប្រធានបទ «ផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug និងAppនានារបស់ក្រសួងមហាផ្ទៃ» នៅបណ្ឌិត្យសភានគរបាលកម្ពុជា

- សហការជាមួយក្រសួងទេសចរណ៍រៀបចំសិក្ខាសាលាផ្សព្វផ្សាយអប់រំស្តីពីគ្រោះថ្នាក់នៃគ្រឿងញៀនក្នុងវិស័យទេសចរណ៍ នៅខេត្តក្រចេះ

- សហការជាមួយក្រុមហ៊ុន អឹម អេស អេ(MSA) រៀបចំផលិតវីដេអូអប់រំខ្លីអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន និងបារីអេឡិចត្រូនិក ព្រមទាំងជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug

- សហការជាមួយតំណាងអង្គការសហប្រជាជាតិទទួលគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) រៀបចំឯកសារកិច្ចប្រជុំភាគីពាក់ព័ន្ធថ្នាក់ជាតិ ស្តីពីការបង្ការ និងការអប់រំអំពីការប្រើប្រាស់គ្រឿងញៀននៅកម្ពុជា

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនបានចំនួន **១៨.២៦៧លើក** (នៅខែមេសា មានចំនួន ១៧.៨៦៦លើក) ច្រើនជាង ៤០១លើក កើនឡើង **២,២%** ដោយគ្របដណ្តប់លើអ្នកមកទទួលយកសារ **១.០៩៣.១៩៩នាក់** ស្រី ៦២៨.០៦៥នាក់ (នៅខែមេសា មានចំនួន ១.០៤១.១១១នាក់) ច្រើនជាង ៥២.០៨៨នាក់ កើនឡើង **៥%**

- បំផុស ផ្សព្វផ្សាយ ជំរុញការទាញយកនិងប្រើប្រាស់នូវកម្មវិធីទូរស័ព្ទដៃ NoDrug រហូតមកដល់ពេលបច្ចុប្បន្ននេះមានចំនួន **៩៤.៣៨៧នាក់** (នៅខែមេសា មានចំនួន ៩០.៨៤៣នាក់) ច្រើនជាង ៣.៥៤៤នាក់ កើនឡើង **៣,៩%**។

## ២. ការពង្រឹងប្រសិទ្ធភាពការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានយកចិត្តទុកដាក់ពង្រឹងគុណភាពសេវាព្យាបាល ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

### ២.១.ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន

សម្របសម្រួលនិងអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- ក្រសួងសុខាភិបាល បានបន្តផ្តល់សេវាព្យាបាលឱសថជំនួសដោយមេតាដូន ដល់អ្នកញៀនហេរ៉ូអ៊ីន ចំនួន **៥០នាក់** ស្រី ៨នាក់ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមន្ទីរបង្អែកច្បារអំពៅ

- អង្គការដៃគូបានអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន ដើម្បីបង្ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺឆ្លងផ្សេងៗតាមឈាម ចំនួន **៧៨០នាក់** ស្រី ១៣៣នាក់(នៅខែមេសា មានចំនួន ៧៧៣នាក់) ច្រើនជាង ៧នាក់ កើនឡើង **១%**។

## ២.២.ការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

សម្របសម្រួល និងពង្រឹងសមត្ថភាពការងារព្យាបាល ស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម ទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- តាមរយៈការព្យាបាលដោយស្ម័គ្រចិត្តនិងផ្អែកលើសហគមន៍ ក្រសួងសុខាភិបាលបានផ្តល់សេវាព្យាបាលដល់អ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន ចំនួន **៣៤៧នាក់** ស្រី ៣៥នាក់ រួមមានមន្ទីរពេទ្យបង្អែកចំនួន ២១៥នាក់ ស្រី ២៧នាក់ និងមណ្ឌលសុខភាពចំនួន ១៣២នាក់ ស្រី ៨នាក់។ ដោយឡែកមណ្ឌលសុខភាពក្នុងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនកែវផុសចំនួន ១.៨០៥នាក់ ស្រី ៦៣នាក់

- ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជន រួមមាន អ្នកចូលថ្មីចំនួន **១.៤៦៦នាក់** ស្រី៧៨នាក់ (ខែមេសា មានចំនួន ១.៧៧៣នាក់ ស្រី១០៣នាក់) អ្នកធ្វើសមាហរណកម្មចំនួន ១.៥៦៨នាក់ ស្រី ២៨នាក់ (ខែមេសា មានចំនួន ១.៦០៣នាក់ ស្រី ១០៣នាក់) និងអ្នកកំពុងស្នាក់នៅចំនួន ៨.៩០៦នាក់ ស្រី ៥៣៦នាក់ (ខែមេសា មានចំនួន ៩.០០៨នាក់ ស្រី ៤៨៦នាក់)

- ចុះពិនិត្យ វាយតម្លៃពីវឌ្ឍនភាពការងារនិងការអនុវត្តនិយាមនីតិវិធីប្រតិបត្តិ(SOP) សម្រាប់មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ និងខេត្តបាត់ដំបង

- ចុះពិនិត្យ វាយតម្លៃការបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ខេត្តកណ្តាល

- រៀបចំបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន ដល់មន្ត្រីបម្រើការងារនៅមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជន ចំនួន ១០មជ្ឈមណ្ឌល នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

- ទទួលប្រតិភូក្រសួងនគរបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះពិនិត្យទីតាំងសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅខេត្តស្វាយរៀង និងចុះទស្សនកិច្ចសិក្សាស្វែងយល់នៅមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ខេត្តព្រះសីហនុ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

ដើម្បីពង្រឹងប្រសិទ្ធភាពការងារអនុវត្តច្បាប់ ឈានទៅបំផ្លាញបណ្តាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀន និងការទប់ស្កាត់ការចរាចរគ្រឿងញៀនគ្រប់ប្រភេទឆ្លងកាត់តំបន់ព្រំដែន បានបន្តសហការសម្របសម្រួលជាមួយស្ថាប័នអនុវត្តច្បាប់ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគីជាមួយអន្តរជាតិ តំបន់ អនុតំបន់ ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

### ៣.១.ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

ក្នុងក្របខ័ណ្ឌនៃការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ បានសហការសម្របសម្រួលក្នុងការរៀបចំ ចូលរួមកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងកម្មវិធីនានា ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- រៀបចំវគ្គបណ្តុះបណ្តាលជំនាញក្នុងការទប់ស្កាត់ បង្ក្រាបការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុគីមីគ្រោះថ្នាក់ផ្សេងៗ តាមប្រព័ន្ធកុំព្យូទ័រ(CBT) ដល់មន្ត្រីតាមនាយកដ្ឋាននិងមន្ទីរពិសោធន៍គ្រឿងញៀនចំណុះអគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ.

- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី១២ របស់មជ្ឈមណ្ឌលព័ត៌មាននិងសម្របសម្រួលសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក(APICC) តាមប្រព័ន្ធអនឡាញ

- ចូលរួមកម្មវិធីទស្សនកិច្ចសិក្សាអន្តរជាតិ សម្រាប់ភាពជាអ្នកដឹកនាំនៃមន្ត្រីអនុវត្តច្បាប់ (IVLP) នៅសហរដ្ឋអាម៉េរិក

- រៀបចំពិធីប្រកាសផ្សព្វផ្សាយសេចក្តីសម្រេច ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យទំនាក់ទំនងព្រំដែន(BLO) តាមប្រព័ន្ធអនឡាញ

- សិក្ខាសាលាស្តីពី «បទដ្ឋានអន្តរជាតិ និងបច្ចុប្បន្នភាពនៃការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម» សម្រាប់អាជ្ញាធរអនុវត្តច្បាប់ រៀបចំដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅរាជធានីភ្នំពេញ

- កិច្ចប្រជុំលើកទី២ របស់ក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រជាតិ និងត្រៀមទទួលការវាយតម្លៃអញ្ញាមញ្ញឆ្នាំ២០២៨-២០២៩ ស្តីពីការប្រឆាំងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ តាមប្រព័ន្ធអនឡាញ

- ទទួលការរាយការណ៍ពីបញ្ហាគ្រឿងញៀន តាមរយៈកម្មវិធីទូរស័ព្ទដៃ NoDrug ចំនួន **១.៥១០ករណី** (នៅខែមេសា មានចំនួន **១.២៩៣**ករណី) ច្រើនជាង ២១៧ករណី កើនឡើង **១៦,៨%** ក្នុងនោះដោះស្រាយរួច ៧៥៤ករណី កំពុងដោះស្រាយ ១៤៩ករណី ព័ត៌មានមិនត្រឹមត្រូវ ៤៤ករណី សាកល្បង ៨ករណី ករណីដដែល ២៥៤ករណី និងផ្សេងៗ ៣០១ករណី

- បញ្ចូលទិន្នន័យព័ត៌មានពាក់ព័ន្ធករណីបង្ក្រាបបទល្មើសគ្រឿងញៀនធំៗចាប់ពី ១គីឡូក្រាមឡើងទៅក្នុងប្រព័ន្ធទិន្នន័យរបស់គម្រោងសុវត្ថិភាពទន្លេមេគង្គ(Safe Mekong Coordination Centre) បានចំនួន ១៤ករណី ជនសង្ស័យ ចំនួន ៧៧នាក់ គ្រឿងញៀនចំនួន ១៣២គីឡូក្រាម។

### ៣.២.លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

តាមរយៈកិច្ចប្រតិបត្តិការរបស់កម្លាំងអនុវត្តច្បាប់ក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- បង្ក្រាបបទល្មើសគ្រឿងញៀនសរុបចំនួន **១.០៥២ករណី**(នៅខែមេសា មានចំនួន ៨១៤ករណី) ច្រើនជាង ២៣៨ករណី កើនឡើង **២៩,២%**។ ឃាត់ខ្លួនជនសង្ស័យសរុបចំនួន **២.៧៩២នាក់** ស្រី ១៧១នាក់ (នៅខែមេសា មានចំនួន ២.២៥១នាក់) ច្រើនជាង ៥៤១នាក់ កើនឡើង **២៤%** ក្នុងនោះ ជនជាតិខ្មែរ ២.៦៥៦នាក់(ស្រី ១៥៤នាក់) និងជនជាតិបរទេស ១៣៦នាក់(ស្រី ១៧នាក់) រួមមាន វៀតណាម ៤៥នាក់ (ស្រី ៦នាក់) ឥណ្ឌូនេស៊ី ៣នាក់ ថៃ ៦នាក់(ស្រី ១នាក់) ម៉ាឡេស៊ី ៤នាក់ ឡាវ ២នាក់ ស្រី ជប៉ុន ១នាក់ និងចិន ៧៥នាក់ (ស្រី ៨នាក់) ក្នុងនោះចិនតៃវ៉ាន់ ២នាក់

- **ចាប់យកគ្រឿងញៀន** ចំនួន **១តោន ៥៥៩គ.ក្រ ៦៤៧,៨៩ក្រាម**(នៅខែមេសា មានចំនួន ១៤៥គ.ក្រ ៤៤៧,៣០ក្រាម) ច្រើនជាង ១តោន ៣១៤គ.ក្រ ២០០,៥៩ក្រាម កើនឡើង **៩០៣,៦%**

– ចាប់យកសារធាតុគីមីផ្សំនិងសារធាតុគីមីពាក់ព័ន្ធ ចំនួន **៨៣៨,៧៣គីឡូក្រាម**

– ចាប់យកកញ្ឆាស្ងួត ចំនួន **២គីឡូក្រាម ២៥៩ក្រាម**

– **ចាប់យកសម្ភារ**ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត រួមមាន រថយន្ត ៣៧គ្រឿង ម៉ូតូ ២៥៩គ្រឿង ទូរស័ព្ទ ១.២៩៤គ្រឿង ជញ្ជីង ១៤៣គ្រឿង អាវុធខ្លី ៨ដើម អាវុធវែង ២ដើម និងរូបិយវត្ថុជាតិ រូបិយប័ណ្ណអន្តរជាតិ(២.១៧៥.៥០០រៀល និង ១៩២.០០០បាត)

– **អនុវត្តដីកា** បានចំនួន ៩៥ដីកា ចាប់ខ្លួនជនសង្ស័យចំនួន ៧៦នាក់

– **ក្នុងចំនួនករណីគ្រឿងញៀនខាងលើ៖**

- ករណីបង្ក្រាបដោយ**សមត្ថកិច្ចនគរបាលចំនួន ៩៥៦ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ២.៥៧២នាក់ (ស្រី ១៤៧នាក់)
- ករណីបង្ក្រាបដោយ**សមត្ថកិច្ចកងរាជអាវុធហត្ថចំនួន ៩៦ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ២២០នាក់ (ស្រី ២៤នាក់)

– **ការកត់សម្គាល់លើបទល្មើសគ្រឿងញៀន៖**

- ករណីធំៗ ចាប់ពី **១គីឡូក្រាម**ឡើង មាន **១៦ករណី** (ចោទពីបទសម្អាតប្រាក់**២ ករណី**) ឃាត់ខ្លួនជនសង្ស័យបាន **៤០នាក់(ស្រី ៧នាក់)** ក្នុងនោះ ខ្មែរ ១០នាក់(ស្រី៣នាក់) វៀតណាម ១៩នាក់ (ស្រី ៤នាក់) នីហ្សេរីយ៉ា ១នាក់ ឥណ្ឌូនេស៊ី ១នាក់ និងចិន ៩នាក់ ចាប់យកគ្រឿងញៀន **១តោន ៤៤០ គីឡូក្រាម ៥២១,៣ក្រាម** សារធាតុគីមីផ្សំនិងសារធាតុគីមីពាក់ព័ន្ធ **៨០៩គីឡូក្រាម ៧២២,៧៥ក្រាម** និង កញ្ឆាក្រៀម **៤,៨៦ក្រាម**
- ករណីមធ្យម ចាប់ពី ១០០ក្រាមឡើង មាន ១១៣ករណី ឃាត់ខ្លួនជនសង្ស័យ ២៥៧នាក់
- ករណីតូចតាច ចាប់ពី ៩៩ក្រាមចុះក្រោម មាន ៩២៣ករណី ឃាត់ខ្លួនជនសង្ស័យ ២.៤៩៤នាក់។

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល

ការចាត់តាំងអនុវត្តវិធានការរដ្ឋបាលបានចំនួន **២.៨៣៩លើក** ក្នុងនោះ ចុះអប់រំម្ចាស់ទីតាំងអាជីវកម្មបាន ២.៥៣៨លើក រួមមាន **៤គោលដៅ** (ផ្ទះសំណាក់ ២០៣លើក ផ្ទះជួល ២.២២០លើក KTV ១០២លើក និងក្លឹប ១៣លើក) និងអញ្ជើញម្ចាស់ទីតាំងអាជីវកម្មមកប្រជុំបាន ៣០១លើក អ្នកចូលរួមចំនួន ១៧.៥៥៣នាក់(ស្រី ៨.៨១៦នាក់)។ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ចុះធ្វើតេស្តរហ័សរកសារធាតុញៀនលើក្រុមគោលដៅបានចំនួន **១៣០លើក** លើមុខសញ្ញាចំនួន **៣២០នាក់**(ស្រី ៥នាក់) រកឃើញវិជ្ជមានសារធាតុញៀន **២២០នាក់** ត្រូវបានសមត្ថកិច្ចបញ្ជូនតាមនីតិវិធីច្បាប់ទៅទទួលយកសេវាបន្សាបនិងព្យាបាល។

### ៣.៤.ការងារមន្ទីរពិសោធន៍គ្រឿងញៀន

– បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន ចំនួន **៥៥៣សំណាក** ស្មើនឹង **៣៥៩ករណី** ក្នុងនោះ សំណាកវិជ្ជមាន សារធាតុញៀន ចំនួន **៩៥,៦៦%**

– បានផលិតតេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង ប្រភេទម៉ាគ្គីតេស្ត (Marquis test) និងប្រភេទម៉ាដេលីន(Merdelin) បានចំនួន **៣.៥០០តេស្ត** និងបានផ្តល់កញ្ចប់រក្សាវត្ថុតាងចំនួន **១០០កញ្ចប់**

– ចូលរួមកិច្ចប្រជុំ ស្តីពីការរៀបចំកម្មេចបារីអេឡិចត្រូនិកនិងវេប ដែលសមត្ថកិច្ចដកហូតក្នុងអំឡុងពេលបង្ក្រាបនាពេលកន្លងមក នៅខេត្តសៀមរាប៖

– ចូលរួមសិក្ខាសាលាពង្រឹងសមត្ថភាពលើការងារត្រួតពិនិត្យផលិតផលថ្នាំដក់ដែលរៀបចំដោយក្រសួងសុខាភិបាល នៅខេត្តកំពង់ឆ្នាំង

– សហការសម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកំពង់ស្ពឺ ចុះពិនិត្យនិងវាយតម្លៃស្ថានភាព ប្រមូល វេចខ្ចប់ និងដឹកជញ្ជូនសារធាតុគីមីនិងសារធាតុគីមីផ្សំដែលស្ថាប័នតុលាការសម្រេចរឹបអូស ដើម្បីយកទៅរក្សាទុកនៅឃ្លាំងសុវត្ថិភាពនៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ រង់ចាំធ្វើការបន្សាបនិងបំផ្លាញចោលដោយសុវត្ថិភាពតាមបច្ចេកទេសវិទ្យាសាស្ត្រ

ជាមួយគ្នានេះ តាមរយៈនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានផ្តល់តេស្តរហ័សរកសារធាតុញៀនតាមទឹកមូត្រប្រភេទមេតំហ្វេតាមីន ចំនួន **៣២.៨៣០តេស្ត** ជូនដល់រដ្ឋបាលរាជធានីភ្នំពេញ ខេត្តបាត់ដំបង ស្ទឹងត្រែង ក្រចេះ សៀមរាប កំពង់ចាម បន្ទាយមានជ័យ រដ្ឋបាលឧត្តរមានជ័យ ស្នងការដ្ឋាននគរបាលខេត្តកណ្តាល កំពង់ស្ពឺ ស្នងការដ្ឋាននគរបាលបាត់ដំបង និងមជ្ឈមណ្ឌលពិភពថ្មីនៃក្តីសង្ឃឹម។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

បានអនុវត្តសកម្មភាពការងារគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំ ដើម្បីបង្ការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវការលួចបង្វែរពីជំនួញស្របច្បាប់ យកទៅកែច្នៃគ្រឿងញៀនខុសច្បាប់ ទទួលបានលទ្ធផលដូចខាងក្រោម៖

– ជំរុញក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បន្តសហការសម្របសម្រួលជាមួយក្រុមហ៊ុន រោងចក្រ សហគ្រាស អំពីការគ្រប់គ្រងការប្រើប្រាស់សារធាតុគីមីផ្សំស្ថិតក្រោមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងគោលការណ៍ណែនាំ

– សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នជំនាញ បន្តជំរុញចុះត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀននៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ឱ្យបានជាប្រចាំ

– បានជួបប្រជុំផ្សព្វផ្សាយ និងពង្រឹងយន្តការគ្រប់គ្រងត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំដើម្បីបង្ការទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់ ជាមួយក្រុមហ៊ុនចំនួន៦ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ

– ក្រសួង ស្ថាប័នជំនាញមានសមត្ថកិច្ចពាក់ព័ន្ធ បានផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស ក្នុងការនាំចូលនូវវត្ថុធាតុដើមផលិតឱសថ និងសារធាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន **៣២.២៥៥តោន ២១៧គ.ក្រ ៦០ក្រាម** និង**១០២,៥០លីត្រ** (នៅខែមេសា មានចំនួន ២២.០៣៧តោន ៩៥០គ.ក្រ) ច្រើនជាង ១០.២១៧តោន ២៦៧គ.ក្រ កើនឡើង **៤៦,៤%**។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

ដើម្បីពង្រឹង និងពង្រីកប្រសិទ្ធភាពក្នុងការសម្របសម្រួលអនុវត្តយន្តការនៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយបណ្តាប្រទេសជាប់ព្រំដែន ជាលទ្ធផលមានដូចខាងក្រោម៖

– បន្តពង្រឹងប្រសិទ្ធភាពការងារការិយាល័យទំនាក់ទំនងព្រំដែន(BLO) រវាងកម្ពុជា-ឡាវ និងកម្ពុជា-វៀតណាម ជាប់ជាប្រចាំ

– បន្តពង្រឹងយន្តការភូមិ ឃុំ សង្កាត់ សគ្មានគ្រឿងញៀន ជាមួយបណ្តាប្រទេសជាប់ព្រំដែន៩

– ចូលរួមកិច្ចប្រជុំពិនិត្យវាយតម្លៃលទ្ធផលកិច្ចសហប្រតិបត្តិការឆ្នាំ២០២៥ និងចុះហត្ថលេខាលើកំណត់ហេតុស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំ២០២៦ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈឡាវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា** និង**ឯកឧត្តម ឧត្តមសេនីយ៍ឯក វ៉ាន់ថង កងម៉ានី រដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈឡាវ** នៅទីស្តីការក្រសួងមហាផ្ទៃ

– ផ្តល់ធាតុចូលលើសេចក្តីព្រាងផែនការសកម្មភាពតំបន់ត្រីកោណមាសឆ្នាំ២០២៦-២០២៧ ក្រោមផែនការប្រតិបត្តិការរួមនៃគម្រោងសុវត្ថិភាពទន្លេមេគង្គ(២០២៣-២០២៧) សម្រាប់ការត្រួតពិនិត្យគ្រឿងញៀនក្នុងចំណោមប្រទេសទាំង៦នៃមហាអនុតំបន់ទន្លេមេគង្គ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា

សម្របសម្រួលកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ និងជាមួយការិយាល័យអង្គការ UNODC បានលទ្ធផលដូចខាងក្រោម៖

– ផ្តល់ធាតុចូលលើសេចក្តីព្រាងបទអន្តរាគមន៍គោរពជូន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** សម្រាប់អញ្ជើញថ្លែងក្នុងកិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍អាស៊ាន-រុស្ស៊ី ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

– ផ្តល់ធាតុចូលលើសេចក្តីព្រាងឯកសារទស្សនទានរបស់សហភាពអឺរ៉ុប ស្តីពីកិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍អាស៊ាន-សហភាពអឺរ៉ុប ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

បន្តពង្រឹងយន្តការ និងធ្វើជាសេនាធិការក្នុងការចាត់តាំងដឹកនាំអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាលក្ខណៈពហុវិស័យនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

– អនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ ចំពោះមន្ត្រីរាជការស៊ីវិល នគរបាលជាតិ យោធិន និងមន្ត្រីជាប់កិច្ចសន្យា មកដល់បច្ចុប្បន្ននេះ**ចំនួន ១៤៥.១០២នាក់** ក្នុងនោះរកឃើញវិជ្ជមានសារធាតុញៀនចំនួន ១១២នាក់ បណ្តេញចេញពីក្របខ័ណ្ឌចំនួន ១០៩នាក់ និងកំពុងតាមដាន ៣នាក់។ ដោយឡែក ក្នុងខែឧសភា ឆ្នាំ២០២៦នេះ ពុំមានក្រសួង ស្ថាប័ន ធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រនោះទេ

– ជំរុញការអនុវត្តបទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា

– ជំរុញក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត បន្តអនុវត្តសេចក្តីណែនាំ ស្តីពីដំណើរការធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ

– ជំរុញការអនុវត្តផែនការសកម្មភាព ស្តីពីការចាត់តាំងអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១៩

– ប្រជុំត្រួតពិនិត្យលើការងាររបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ខែមេសា និងលើកទិសដៅការងារខែឧសភាឆ្នាំ២០២៦ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ជួបជាមួយក្រុមការងារអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីពិភាក្សាការរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីចំណេះដឹងនិងគ្រោះថ្នាក់នៃគ្រឿងញៀន ជូនដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា នៅអគ្គលេខាធិ-ការដ្ឋានរដ្ឋសភា

– ចូលរួមធ្វើបទឧទ្ទេសនាមក្នុងសិក្ខាសាលាបណ្តុះបណ្តាលផលប៉ះពាល់នៃការប្រើប្រាស់និង ការជួញដូរគ្រឿងញៀន ដល់និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៃសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ ខេត្តព្រៃវែង

– ប្រជុំត្រៀមរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ចូលរួមវគ្គបណ្តុះបណ្តាលវិធីសាស្ត្រអង្កេត ស្តីពីការយល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហា គ្រឿងញៀន នៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

– បន្តសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត ជំរុញឱ្យមានប្រសិទ្ធភាពការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន និងការបង្ក្រាបបទល្មើសគ្រឿងញៀន នៅតាមបណ្តាភូមិសាស្ត្រស្មុគស្មាញ។

**ក្រៅពីលទ្ធផលសកម្មភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខាងលើ អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងមន្ត្រី** ចូលរួមដូចខាងក្រោម៖

– ពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងក្រុមប្រឹក្សារាជធានី ខណ្ឌ សង្កាត់ និងមន្ទីរនានាជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតី-តេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា** នៅរាជធានីភ្នំពេញ

– ក្នុងព្រឹត្តិការណ៍ប្រកួតកីឡាឆ្លងកាត់ឧបសគ្គ ពានរង្វាន់ «**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងលោកជំទាវ **កែ សួនសុភី ស សុខា**» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅបណ្ឌិត្យសភានគរបាលកម្ពុជា

– កិច្ចប្រជុំរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** នៅទីស្តីការក្រសួងមុខងារសាធារណៈ

– ស្តាប់បទបង្ហាញ ស្តីពីប្រវត្តិនិងស្ថានភាពព្រំដែនកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **ឡាំ ជា** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន និងឯកឧត្តមសន្តិបណ្ឌិត **ម៉ៅ ច័ន្ទតារា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំអន្តរក្រសួង ស្តីពីរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០ ដែលរៀបចំដោយក្រសួងផែនការ នៅរាជធានីភ្នំពេញ

– ពិធីប្រកាសចូលកាន់មុខតំណែងអភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ៰

– កិច្ចប្រជុំអន្តរក្រសួងកម្រិតថ្នាក់ដឹកនាំ ដើម្បីពិនិត្យនិងពិភាក្សាចុងក្រោយលើសេចក្តីព្រាងរបាយការណ៍តាមដាននិងត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ឆ្នាំ២០២៥ និងលើសេចក្តីព្រាងរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំត្រីមាស ឆ្នាំ២០២៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី

– កិច្ចប្រជុំស្តីពីការការរៀបចំផែនការសកម្មភាពរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក សង្កាត់ទាក់ទងនឹងការប្រើប្រាស់ថវិកាសេវាសង្គម នៅទីស្តីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំប្រចាំខែឧសភា ដើម្បីពិភាក្សាលើរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## III. ទិសដៅការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខែមិថុនា ឆ្នាំ២០២៦

ដើម្បីបន្តអនុវត្តឱ្យមានប្រសិទ្ធភាពលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានដាក់ចេញនូវទិសដៅការងារសម្រាប់ខែមិថុនា ឆ្នាំ២០២៦ ដូចខាងក្រោម៖

### ១. ការផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** បន្តសហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ពង្រឹងការងារផ្សព្វផ្សាយអប់រំ តាមរយៈវិទ្យុ ទូរទស្សន៍ ទូរស័ព្ទដៃ សិល្បៈភាពយន្ត លើស្លាកសញ្ញាផលិតផលក្នុងស្រុក និងតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមផ្សេងទៀត។

**១.២.** បន្តសម្របសម្រួលនិងជំរុញក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ផលិតមាតិកាពាក់ព័ន្ធការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន។

**១.៣.** បន្តសហការនិងជំរុញរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជំរុញការទាញយក និងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug។

**១.៤.** បន្តពង្រឹងការបញ្ជ្រាបខ្លឹមសារអប់រំអំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនតាមរយៈសកម្មភាពផ្សេងៗរបស់ដៃគូ។

**១.៥.** បន្តសហការនិងសម្របសម្រួលដើម្បីត្រៀមរៀបចំចុះអនុស្សរណៈនៃការយោគយល់រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សហព័ន្ធកីឡាបាល់ទាត់ និងសហភាពសហព័ន្ធយុវជនកម្ពុជា។

**១.៦.** បន្តចលនា កៀរគរឱ្យមានការចូលរួមផុលផុសនិងគាំទ្រពីគ្រប់មជ្ឈដ្ឋានសង្គមលើការងារផ្សព្វផ្សាយអប់រំ ស្តីពីបញ្ហាគ្រឿងញៀន។

**១.៧.** បន្តសហការជាមួយបណ្តាញគ្រីស្ទបរិស័ទនៃក្រុមប្រឹក្សាបណ្តាញព្រះវិហារគ្រីស្ទបរិស័ទកម្ពុជា ដើម្បីអនុវត្តកម្មវិធីគ្រួសាររឹងមាំ ( Strong Family )។

**១.៨.** បន្តសម្របសម្រួលជាមួយគណៈកម្មាធិការសម្របសម្រួល ជំរុញ អនុវត្ត និងត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ រៀបចំសកម្មភាពផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងកម្មវិធីទូរស័ព្ទដៃ NoDrug នៅខេត្តព្រៃវែង។

**១.៩.** បន្តសហការជាមួយក្រសួងព័ត៌មាននិងជាប្រធានគណៈកម្មការទទួលបន្ទុកផ្សព្វផ្សាយអប់រំ ដើម្បីបញ្ចប់ការផលិតវីឌីអូសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនសម្រាប់ត្រៀមចាក់ផ្សាយក្នុងទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**១.១០.** បន្តសហការជាមួយក្រុមហ៊ុនMSA ដើម្បីបញ្ចប់ការផលិតវីដេអូអប់រំ ស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug។៥

**១.១១.**បន្តសហការជាមួយក្រសួងទេសចរណ៍រៀបចំវគ្គផ្សព្វផ្សាយអប់រំចូលរួមធ្វើបទបង្ហាញស្តីពីគ្រោះថ្នាក់នៃគ្រឿងញៀនក្នុងវិស័យទេសចរណ៍ នៅខេត្តកំពង់ចាម។

**១.១២.** បន្តកៀរគរដៃគូMOU ផលិតបទចម្រៀងអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន។

## ២. ការពង្រឹងប្រសិទ្ធភាពការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

**២.១.** បន្តសហការជាមួយក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការទទួលទិន្នន័យ និងធ្វើបច្ចុប្បន្នភាពអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន។

**២.២.** បន្តជំរុញមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជនឱ្យរៀបចំមាតិកាសម្រាប់ដាក់លើកម្មវិធីទូរស័ព្ទដៃ NoDrug។

**២.៣.** បន្តរៀបចំបណ្តុះបណ្តាលការអនុវត្តផ្ទាល់ ការប្រើប្រាស់ថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន ដល់មន្ត្រីបម្រើការងារនៅតាមមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជន។

**២.៤.** បន្តសម្របសម្រួលជាមួយតំណាងក្រសួងនគរបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមពន្លឿននីតិវិធីក្នុងការស្នើសុំជំនួយសម្រាប់សាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅខេត្តស្វាយរៀង។

**២.៥.** បន្តសម្របសម្រួលជាមួយអគ្គនាយកដ្ឋានស្តារសម្បទានៃក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្នុងការរៀបចំស្តង់ពិព័ណ៌របស់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ក្នុងកម្មវិធីទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**២.៦.** ត្រៀមចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពីការព្យាបាល និងការថែទាំសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀនប្រភេទរំញោច តាមប្រព័ន្ធអនឡាញ។

**២.៧.** ត្រៀមចូលរួមកិច្ចប្រជុំលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតីសម្បទាអ្នកញៀនគ្រឿងញៀន។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

**៣.១.** បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ក្នុងការទប់ស្កាត់ជាអាទិភាពនូវការចរាចរគ្រឿងញៀនឆ្លងកាត់ព្រំដែន តាមផ្លូវគោក ទឹក អាកាស និងបញ្ញើប្រៃសណីយ៍។

**៣.២.** ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលជំនាញក្នុងការទប់ស្កាត់ បង្ក្រាបការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុគីមីគ្រោះថ្នាក់ផ្សេងៗ តាមប្រព័ន្ធកុំព្យូទ័រ(CBT) ដល់មន្ត្រីតាមបណ្តានាយកដ្ឋាននិងមន្ទីរពិសោធន៍គ្រឿងញៀនចំណុះអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.។

### ៣.៣. ការងារមន្ទីរពិសោធន៍គ្រឿងញៀន៖

- បន្តពិនិត្យ និងធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន ដើម្បីដោះស្រាយការកកស្ទះសំណុំរឿងរបស់សាលាដំបូងរាជធានី ខេត្ត
- បន្តផលិតឧបករណ៍តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូងប្រភេទម៉ាគ្វីតេស្ត ( Marquis test) និងកេតាមីនតេស្ត ( Ketamine test ) ដើម្បីមានលទ្ធភាពផ្គត់ផ្គង់ឧបករណ៍ទាំងនេះ ដល់ស្ថាប័នអនុវត្តច្បាប់ សម្រាប់ប្រើប្រាស់ឱ្យបានគ្រប់គ្រាន់
- ត្រៀមចូលរួមធ្វើតេស្តរកសារធាតុញៀនក្នុងទឹកមូត្រជូនដល់មន្ត្រីរាជការតាមក្រសួងស្ថាប័ន អង្គភាពមួយចំនួន៖

– ត្រៀមរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីការបំផ្លាញនិងចាត់ចែងដោយសុវត្ថិភាពនូវវត្ថុតាង ជាសារធាតុញៀន សារធាតុគីមីផ្សំ សារធាតុគីមីពាក់ព័ន្ធ និងបារីអេឡិចត្រូនិក ដែលបានចាប់យកក្នុង ប្រតិបត្តិការរបស់មន្ត្រីអនុវត្តច្បាប់ នៅអគ្គលេខាធិការដ្ឋាន នៃអ.ជ.ប.គ.ញ.

– ត្រៀមចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការវិភាគគ្រឿងញៀនតាមបច្ចេកទេសកោសល្យវិច័យ នៅប្រទេសចិន។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

**៤.១.** បន្តចុះជួបប្រជុំផ្សព្វផ្សាយ និងពង្រឹងយន្តការគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងអង្គភាពគយនិងរដ្ឋាករតាមច្រកទ្វារព្រំដែន។

**៤.២.** បន្តសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំ នៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ដើម្បីបង្ការទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់។

**៤.៣.** ត្រៀមសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រៀបចំសិក្ខាសាលា ស្តីពីការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីផ្សំរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុនរោងចក្រក្នុងវិស័យឧស្សាហកម្ម ដើម្បីបង្ការទប់ស្កាត់ការលួចបង្វែរយកទៅផលិតគ្រឿងញៀនខុសច្បាប់។

**៤.៤.** ត្រៀមរៀបចំសិក្ខាសាលា ស្តីពីការពង្រឹងប្រសិទ្ធភាពកិច្ចសហការគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីផ្សំ រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុន រោងចក្រ ដើម្បីបង្ការ ទប់ស្កាត់ការលួចបង្វែរយកទៅផលិតគ្រឿងញៀនខុសច្បាប់។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

**៥.១.** បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ទ្វេភាគី ត្រីភាគី ពហុភាគី ជាមួយប្រទេសជាប់ព្រំដែន តាមរយៈការអនុវត្តតាមកំណត់ហេតុកិច្ចប្រជុំដែលបានឯកភាព ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៥.២.** បន្តសម្របសម្រួល និងសហការជាមួយប្រទេសជាប់ព្រំដែន ដើម្បីពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រំដែន(BLO)។

**៥.៣.** ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទ្វេភាគី ត្រីភាគី កម្ពុជា-វៀតណាម-ឡាវ លើកទី១៩ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

**៥.៤.** ត្រៀមរៀបចំទទួលគណៈប្រតិភូវៀតណាមក្នុងការសិក្សាទីតាំងសាងសង់មជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនស្វាយរៀង។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

**៦.១.** បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូ ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៦.២.** បន្តចូលរួមសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូ នៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាពិសេសបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ។៸

**៦.៣.** បន្តសម្របសម្រួលអំពីវឌ្ឍនភាព នៃសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា(MOU) ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមលម្ហសមុទ្រ រវាងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយកងកម្លាំងឆ្មាំសមុទ្រនៃសាធារណៈរដ្ឋកូរ៉េ។

**៦.៤.** ត្រៀមរៀបចំសម្របសម្រួលក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនរវាង**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការនៃ អ.ជ.ប.គ.ញ.** និងតំណាងរដ្ឋបាលប្រឆាំងគ្រឿងញៀនសហរដ្ឋអាមេរិកប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក នៅអគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ.។

**៦.៥.** ត្រៀមចូលរួមកម្មវិធីផ្សព្វផ្សាយ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនរបស់សិង្ហបុរីលើកទី៣ ឆ្នាំ២០២៦ តាមប្រព័ន្ធអនឡាញ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**៧.១.** បន្តពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៧.២.** បន្តពង្រឹងការអនុវត្តបទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។

**៧.៣.** បន្តជំរុញអនុវត្តផែនការ ស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១។

**៧.៤.** បន្តសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ដើម្បីរៀបចំ និងកែសម្រួលសេចក្តីប្រកាសស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការពន្យារការចាប់ខ្លួន ឬការរឹបអូសវត្ថុតាង សំដៅឱ្យអាជ្ញាធរមានសមត្ថកិច្ចអាចតាមដាន ស្វែងរក ឬបង្ក្រាបការជួញដូរគ្រឿងញៀន និងការញ៉ុះញង់ឱ្យលក់ដោយខុសច្បាប់។

**៧.៥.** ត្រៀមចូលរួមដំណើរការអង្កេត ស្តីពីការយល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហាគ្រឿងញៀន។

**៧.៦.** ត្រៀមចូលរួមកិច្ចប្រជុំអន្តរក្រសួងកម្រិតថ្នាក់ដឹកនាំ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។

**៧.៧.** ត្រៀមរៀបចំប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦។

**៧.៨.** ត្រៀមរៀបចំពិធីផ្សព្វផ្សាយផែនការសកម្មភាព ស្តីពីការចាត់តាំងអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១។

**អគ្គលេខាធិការ**

នាយឧត្តមសេនីយ៍ **មាស-វីរិទ្ធ**

**ចម្លងជូន៖**

- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.
  "ដើម្បីគោរពជូនជ្រាប"
- ឯកឧត្តមអនុប្រធាន និងសមាជិក អ.ជ.ប.គ.ញ.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- អគ្គលេខាធិការរងនៃអ.ជ.ប.គ.ញ.
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី
- នាយកដ្ឋាននិងមន្ទីរពិសោធន៍នៃ អ.ជ.ប.គ.ញ.
  "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ